# ស្ថានទូតអូស្ត្រាលី
# រាជធានីភ្នំពេញ

## សេចក្តីប្រកាសពត៌មាន

## ស្ថានទូតអូស្ត្រាលីប្រគល់ជូនសៀវភៅដល់បណ្ណាល័យ នៃសាកលវិទ្យាល័យភ្នំពេញដើម្បីអបអរទិវាជនជាតិដើមអូស្ត្រាលី

ក្នុងឱកាសនៃសប្តាហ៍ NAIDOC ២០១៣ កាលពីថ្ងៃទី១២ ខែកក្កដា នេះ លោក **ដេវ ហ្គោច** (Dave Gordge) ប្រធានបេសកកម្មស្ដីទីនៃស្ថានទូតអូស្ត្រាលី បានប្រគល់ជូនសៀវភៅស្តីអំពីសិល្បៈជនជាតិដើមអូស្ត្រាលីចំនួនពីរក្បាល ជូនដល់បណ្ណាល័យ ហ៊ុន សែន នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

ស្ថានទូតអូស្ត្រាលីសង្ឃឹមថា សៀវភៅទាំងនេះអាចជួយជាធនធានដល់ពលរដ្ឋកម្ពុជាដែលមានបំណងសិក្សាបន្ថែមអំពីវប្បធម៌របស់ជនជាតិដើមអូស្ត្រាលី។

ពិធីបុណ្យសប្តាហ៍ NAIDOC ត្រូវបានប្រារព្ធធ្វើឡើងពាសពេញផ្ទៃប្រទេសអូស្ត្រាលី និងពិភពលោកជារៀងរាល់ខែកក្កដា ដើម្បីអបអរប្រវត្តិសាស្ត្រ វប្បធម៌ និង សមិទ្ធិផលនានារបស់ជនជាតិដើមអូស្ត្រាលី និង ជនជាតិដើមប្រជុំកោះ តូរេស ស្រេដ ។

ជនជាតិដើមអូស្ត្រាលីបានមកដល់ប្រទេសអូស្ត្រាលីពីទ្វីបអាស៊ីតាំងពី ៥០.០០០ឆ្នាំមុនមកម្លេះ។ ពួកគេបានបង្កើតជាកុលសម្ព័ន្ធជាច្រើនផ្សេងៗគ្នា ហើយប្រកបមុខរបរភាគច្រើនជាអ្នកប្រមាញ់ និងអ្នកប្រមូលផលពីធនធានធម្មជាតិ ។ ជនជាតិដើមប្រជុំកោះ តូរេស ស្រេដ បានមករស់នៅលើកោះដែលស្ថិតនៅខាងជើងទឹកដីរវាងរដ្ឋ Queensland និងប្រទេស Papua New Guinea កាលពី ១០.០០០ឆ្នាំមុន។

បច្ចុប្បន្ននេះ ជនជាតិដើមអូស្ត្រាលី និង ជនជាតិដើម តូរេស ស្រេដ កំពុងរស់នៅតាមបណ្តាទីក្រុង និងទីប្រជុំជននានា ប៉ុន្តែភាគច្រើននៅតែរស់នៅតាមទីជនបទដាច់ស្រយ៉ាលនៅឡើយ ដោយប្រកាន់ខ្ជាប់ប្រពៃណីរបស់ពួកគេ។

ជនជាតិដើមអូស្ត្រាលីមានវប្បធម៌ចំរុះ និងរឹងមាំ ហើយបានចូលរួមចំណែកយ៉ាងសំខាន់ដល់អត្តសញ្ញាណជាតិរបស់ប្រទេសអូស្ត្រាលី ។ ជនជាតិដើម និង ជនជាតិដើមប្រជុំកោះតូរេស ស្រេដ អាយស្លេនឌ័រ ចូលរួមចំណែកយ៉ាងសំខាន់ដល់វិស័យជាច្រើនដោយរាប់បញ្ចូលទាំង សិល្បៈ សារពត៌មាន វិស័យអប់រំ នយោបាយ កីឡា និងធុរកិច្ច ។

No 16B, National Assembly Street, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413

NAIDOC មានន័យថា″ គណៈកម្មការជាតិប្រត្តិបត្តិទិវាជនជាតិដើមនិងជនជាតិប្រជុំកោះ″។ គណៈកម្មការនេះទទួលខុសត្រូវក្នុងការរៀបចំសកម្មភាពជាតិនានាក្នុងអំឡុងពេលសប្តាហ៍ NAIDOC ហើយអក្សរកាត់របស់គណៈកម្មការនេះបានក្លាយទៅជាឈ្មោះរបស់ពិធីបុណ្យសប្តាហ៍នេះតែម្តង។ សប្តាហ៍ NAIDOC ត្រូវបានប្រារព្ធធ្វើឡើងមិនតែចំពោះសហាគមន៍ជនជាតិដើមប៉ុណ្ណោះទេ តែសំរាប់ពលរដ្ឋអូស្ត្រាលីគ្រប់រូបផងដែរ។

***សំរាប់ពត៌មានបន្ថែមសូមទាក់ទង:***


លោក **ដេវ ហ្គោច** (Dave Gordge) អ្នកនាំពាក្យនៃស្ថានទូតអូស្ត្រាលីប្រចាំរាជធានីភ្នំពេញ

Email: dave.gordge@dfat.gov.au

ទូរស័ព្ទលេខ: ០២៣ ២១៣ ៩៧០ លេខបន្ត: ៥០២


ថ្ងៃទី១២ ខែ កក្កដា ឆ្នាំ ២០១៣